# 2 ការយល់ដឹង និងការរៀបចំចលនា ដើម្បីសុខភាពសហគមន៍

**នៅក្នុងជំពូកនេះ :** **ទំព័រ**


ការរៀបចំចលនាដើម្បីសុខភាពបរិស្ថាន . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . 12
ការផ្លាស់ប្តូរត្រូវការពេលវេលា . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . 13
សកម្មភាពសម្រាប់ការរៀនសូត្រ និងចលនា . . . . . . . . . . . . . . . . . . . . . . . . . . . . . .14
ស្ត្រីត្រូវការបញ្ចេញយោបល់ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .14
ការពិភាក្សាដែលមានការណែនាំ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . 15
ការគូរផែនទីសហគមន៍ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . 15
ការស្វែងយល់អំពីអ្វីដែលសហគមន៍ត្រូវការ . . . . . . . . . . . . . . . . . . . . . . . . . . . . . . 15
ការដើរសង្កេតមើលបញ្ហាសុខភាព . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .16
ការផ្លាស់ប្តូរតាមពេលវេលា . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .16
សកម្មភាពគូររូប . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .16
ការស្ទង់មតិក្នុងសហគមន៍ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .17
ល្ខោន . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .17
ការណែនាំអំពីពេលវេលាដែលគួរប្រើសកម្មភាពនីមួយៗ . . . . . . . . . . . . . . . . . . . . . . .19

# ការយល់ដឹង និងការរៀបចំចលនា ដើម្បីសុខភាពសហគមន៍




នៅពេលមាលានិងអ្នកលើកកម្ពស់សុខភាពដទៃទៀត ដឹងថាប្រជាជនជាច្រើននៅក្នុងក្រុងមែនក្លាវ៉ាល់តូ កំពុងតែមានជំងឺជាបន្តបន្ទាប់, ពួកគេបានយល់ដឹងយ៉ាងឆាប់រហ័សថា បញ្ហានោះគឺជាជំងឺអាសន្នរោគ ដែលជាបញ្ហាសុខភាពមួយក្នុងសហគមន៍ បណ្ដាលមកពីកត្តាបរិស្ថានគឺ ទឹកមិនស្អាត។ អ្នកលើកម្ពស់សុខភាព និងអ្នកអប់រំសុខភាពក្នុងភូមិ បានទៅជួបជាមួយប្រជាជនពីផ្ទះមួយទៅផ្ទះមួយ ដើម្បីពួកគេគ្រប់គ្នាឲ្យយល់ពីបញ្ហានេះ និងពីអ្វីដែលគួរធ្វើ។ នៅពេលការព្យាបាលសំខាន់ៗបានទទួលជោគជ័យ ប្រជាជនក៏មានទំនុកចិត្ត ហើយសហគមន៍ទាំងមូលក៏ចាប់ផ្ដើមពិភាក្សារិះរកមូលហេតុឫសគល់នៃជំងឺអាសន្នរោគនិងបញ្ហាសុខភាពដទៃៗទៀត។

តាមរយៈការចូលរួមក្នុងការអប់រំនៅក្នុងសហគមន៍ស្ដីអំពីមូលហេតុឫសគល់នៃបញ្ហា ប្រជាជនបានចាប់ផ្ដើមកែលម្អសុខភាពបរិស្ថានលើផ្នែកជាច្រើន។ ការកែលម្អនៅក្នុងផ្នែកនីមួយៗ ធ្វើឲ្យអ្នកភូមិកាន់តែជឿជាក់លើខ្លួនឯងនូវលទ្ធភាពក្នុងការផ្លាស់ប្ដូរជីវិតរបស់ខ្លួន។

ដើម្បីស្វែងរកមូលហេតុនៃបញ្ហាសុខភាពមួយ អ្នកអប់រំសុខភាពត្រូវសួរសំនួរជាច្រើននិងប្រមូលព័ត៌មានតាមវិធីផ្សេងៗ។ មានជម្លោះជាច្រើនកើតឡើងនៅក្នុងសហគមន៍ ដែលតម្រូវឲ្យមានការពិភាក្សាគ្នារយៈពេលយូរ និងការព្យាយាមដោះស្រាយបញ្ហាទាំងនេះ។ ខណៈដែលសហគមន៍នីមួយៗនឹងស្វែងរកវិធីរៀងៗខ្លួនឆ្ពោះទៅកាន់ការផ្លាស់ប្ដូរ និងរិះរកសកម្មភាពផ្សេងៗដើម្បីរៀបចំការផ្លាស់ប្ដូរនោះ, យើងមានបទពិសោធន៍ពីគម្រោង"សុខភាពសម្រាប់ប្រជាជន" សម្រាប់ធ្វើជាឧទាហរណ៍មួយចំនួនស្ដីអំពីវិធីដែលសហគមន៍ទាំងឡាយអាចស្វែងរកមូលហេតុឫសគល់នានានៃបញ្ហាសុខភាពបរិស្ថាន និងធ្វើសកម្មភាពផ្លាស់ប្ដូរបញ្ហាទាំងនោះ។

# ការរៀបចំចលនាដើម្បីសុខភាពបរិស្ថាន

បន្ទាប់ពីការរស់នៅក្នុងភាពក្រីក្រនិងដាច់ស្រយាលអស់ជាច្រើនឆ្នាំមក ប្រជាជននៅឆ្នេរអេខ្វាឌ័រដែលរស់នៅលើភ្នំតូចៗដែលសម្បូរទៅដោយភក់ ក៏បានបាត់បង់ក្តីសង្ឃឹម។ ពួកគេមិនដឹងថាគួរធ្វើឲ្យជីវភាពបានល្អប្រសើរដោយមធ្យោបាយណាទេ។ ជីវភាពប្រចាំថ្ងៃជួបការលំបាកជាខ្លាំង។ ប្រជាជនពិបាកនឹងជឿជាក់លើការរៀបចំផែនការសម្រាប់អនាគត ថាអាចបានល្អប្រសើរឡើយ។

តាមរយៈការធ្វើការងារដើម្បីដោះស្រាយបញ្ហាសុខភាពចំពោះមុខ(ជំងឺអាសន្នរោគ) មាលានិងបុគ្គលិកសុខាភិបាលនៃគម្រោង"សុខភាពសម្រាប់ប្រជាជន" បានជួយសង្គ្រោះជីវិតប្រជាជនជាច្រើននាក់។ ជោគជ័យរបស់អ្នកលើកកម្ពស់សុខភាព អង្គការក្នុងស្រុក និងអ្នកភូមិទាំងអស់ ក្នុងការបញ្ឈប់ការរាតត្បាតជំងឺ, បានជំរុញទឹកចិត្តនិងត្រៀមលក្ខណៈពួកគេឲ្យជំនះលើបញ្ហាដទៃទៀតផងដែរ។ នៅពេលព្យុះដ៏ធំបានបំផ្លាញសមិទ្ធិផលយ៉ាងច្រើនរបស់ខ្លួន ពួកគេអាចរៀបចំខ្លួននិងស្រោចស្រង់ឡើងវិញពីការបំផ្លាញរបស់ព្យុះនោះ។ បន្ទាប់មកពួកគេអាចបន្តសកម្មភាពរបស់ខ្លួនដើម្បីដោះស្រាយបញ្ហាដទៃៗទៀត។ ការងាររបស់ពួកគេក្នុងការធ្វើឲ្យសហគមន៍មានសុខភាពល្អប្រសើរ គឺនៅតែបន្ត ព្រោះពួកគេកំពុងកែលម្អស្ថានភាពបច្ចុប្បន្ន និងប្រឹងប្រែងដើម្បីអនាគតរបស់ខ្លួន។

## ការស្វែងយល់អំពីមូលហេតុឫសគល់

បញ្ហាសុខភាពនានាអាចបណ្ដាលមកពីមូលហេតុជាច្រើន ដូចជាមេរោគ សារធាតុគីមីពុល ឧប្បត្តិហេតុ ភាពអត់ឃ្លាន ការប្រឈមនឹងកម្ដៅខ្លាំង ឬភាពត្រជាក់ខ្លាំង ។ល។ ទាំងនេះគឺជាមូលហេតុផ្ទាល់នៃជំងឺ។ ជំងឺអាចមានមូលហេតុផ្ទាល់ ប៉ុន្តែវាក៏អាចមានមូលហេតុឫសគល់របស់វាដែរ។




ការស្វែងរកមូលហេតុឫសគល់អាចជួយយើងឲ្យកំណត់អំពីអ្វីដែលយើងត្រូវធ្វើដើម្បីដោះស្រាយបញ្ហាក្នុងរយៈពេលវែងឆ្ងាយ។ សកម្មភាព "ប៉ុន្តែហេតុអ្វី...?" ដែលមាលាបានរៀបចំជាមួយអ្នកភូមិ(មើលទំព័រ7) អាចជួយប្រជាជនឲ្យយល់ថា បញ្ហាតែមួយអាចបណ្ដាលមកពីមូលហេតុឫសគល់ជាច្រើនខុសៗគ្នា។

# ការផ្លាស់ប្តូរត្រូវការពេលវេលា

ការកែលម្អសុខភាពបរិស្ថាន មិនមែនកើតឡើងយ៉ាងឆាប់រហ័សទេ។ នៅទីក្រុងមែនក្លារ៉ាល់គូ បុគ្គលិកសុខាភិបាលបានព្យាបាលជំងឺអាសន្នរោគដោយការផ្តល់ភេសជ្ជៈបង្គ្រប់ជាតិទឹកជាមុន និងក៏បានធ្វើការងារផ្សេងទៀតដើម្បីបង្ការជំងឺ តាមរយៈការធ្វើឲ្យទឹកមានសភាពស្អាត។ បន្ទាប់មកពួកគេបានរៀបចំចាត់ចែងសហគមន៍ឲ្យសាងសង់ប្រព័ន្ធទឹកស្អាតនិងបង្គន់ ដើម្បីការពារជំងឺអាសន្នរោគនៅថ្ងៃមុខទៀត។ ប៉ុន្តែជាអកុសល ពួកគេបានយល់ដឹងអំពីបញ្ហាសំណឹកដី និងទឹកជំនន់ដែលបណ្តាលមកពីការបាត់បង់ដើមឈើ នៅក្រោយពេលដែលព្យុះដ៏ធំបានបំផ្លាញប្រព័ន្ធទឹកស្អាតនិងបង្គន់ខ្ទេចខ្ទីរួចអស់ទៅហើយ។ ពួកគេត្រូវយល់អំពីមូលហេតុឫសគល់របស់វា ទើបអាចធ្វើការផ្លាស់ប្តូរដែលស្ថិតស្ថេរបាន។




ជួនកាលយើងត្រូវតែពុះពារ និងទទួលបរាជ័យជាច្រើនដង មុននឹងសម្រេចបានជោគជ័យ។ ធម្មតាយើងគ្រាន់តែសង្កេតមើលថាអ្វីមានប្រសិទ្ធភាព, អ្វីគ្មានប្រសិទ្ធភាព, ហើយវាមកពីមូលហេតុអ្វី។ ការកែលម្អសុខភាពបរិស្ថាន ត្រូវការពេលវេលា ព្រោះជាធម្មតាវាត្រូវការការផ្លាស់ប្តូរផ្សេងៗគ្នាចំនួនបួនយ៉ាង ៖

- ការផ្លាស់ប្តូរដើម្បីកែលម្អប្រព័ន្ធទឹក, ផ្ទះសម្បែង, ឬអ្វីផ្សេងទៀតដែលយើងសាងសង់ដើម្បីខ្លួនយើង(រចនាសម្ព័ន្ធ)។
- ការផ្លាស់ប្តូរលើអ្វីដែលយើងទិញ ដូចជាការបដិសេធមិនទិញអាហារសល់, ផលិតផលសម្អាតដែលមានជាតិពុល, ឬផលិតផលដែលវេចខ្ចប់ក្នុងថង់ប្លាស្ទិក(ការចំណាយលើការប្រើប្រាស់)។
- ការផ្លាស់ប្តូរទម្លាប់ ដូចជាការលាងសម្អាតដៃទៀងទាត់, ការដាក់សំណល់ដាច់ដោយឡែកពីគ្នាដើម្បីអាចកែច្នៃឡើងវិញនូវកាកសំណល់មួយចំនួន, ឬការដាំដំណាំតាមវិធីថ្មីៗ(ការប្រព្រឹត្ត)។
- ការផ្លាស់ប្តូរលើអំណាចដែលអ្នកភូមិ សាជីវកម្ម រដ្ឋាភិបាល និងមនុស្សដទៃទៀតអាចសម្រេចធ្វើអ្វីមួយដែលប៉ះពាល់ដល់បរិស្ថាន(នយោបាយ)។

ការផ្លាស់ប្តូរទាំងអស់នេះ ត្រូវការពេលវេលា, ហើយវាទទួលឥទ្ធិពលចំពោះគ្នាទៅវិញទៅមក។

### ធ្វើការជាមួយមនុស្សវ័យក្មេង

វិធីមួយដើម្បីធានាថា ការផ្លាស់ប្តូរនឹងនៅស្ថិតស្ថេរយូរអង្វែង គឺត្រូវធ្វើការជាមួយមនុស្សវ័យក្មេង ព្រោះពួកគេនឹងនាំយកនូវអ្វីដែលបានរៀនសូត្រទៅថ្ងៃអនាគត។ យើងគ្រប់គ្នា ទោះជាមានអាយុប៉ុន្មានក្តី សុទ្ធតែអាចយកតម្រាប់តាមអាកប្បកិរិយារបស់មនុស្សវ័យក្មេង ពោលគឺពួកគេតែងតែមានឆន្ទៈរៀនសូត្រនិងសាកល្បងអ្វីៗដែលថ្មី។

*យើងត្រូវតែធ្វើជាអ្នកផ្លាស់ប្តូរដែលយើងចង់ឃើញនៅក្នុងពិភពលោក។*

# សកម្មភាពសម្រាប់ការរៀនសូត្រ និងចលនា

សកម្មភាពជាក្រុម អាចជួយប្រជាជនឲ្យយល់អំពីមូលហេតុឫសគល់នៃបញ្ហា រួចបង្កើតផែនការសម្រាប់ការផ្លាស់ប្តូរ។ សកម្មភាពដែលអ្នកប្រើប្រាស់ នឹងអាស្រ័យលើអ្វីដែលអ្នកត្រូវដឹង, អ្វីដែលអ្នករំពឹងនឹងធ្វើ, និងលើធនធានដែលមាន។ សកម្មភាពនានាអាច ៖

- ប្រមូលប្រជាជនឲ្យមកជួបជុំគ្នា ដើម្បីកំណត់អំពីបញ្ហារួម។
- ស្វែងរកនូវអ្វីដែលប្រជាជនគិតថាពួកគេត្រូវការបំផុត។
- ប្រមូលព័ត៌មានផ្សេងៗអំពីអ្វីដែលបណ្តាលឲ្យមានបញ្ហាសុខភាព។
- វិភាគបញ្ហាទាំងឡាយ ដើម្បីរកឲ្យឃើញនូវមូលហេតុផ្ទាល់ និងមូលហេតុឫសគល់របស់វា។
- ប្រមូលគំនិតយោបល់របស់ប្រជាជនទាំងអស់នៅក្នុងសហគមន៍។ គម្រោងមួយមិនអាចទទួលបានជោគជ័យទេ បើក្រុមខ្លះឬយោបល់មួយចំនួន មិនត្រូវបានរាប់បញ្ចូល។ ប្រជាជននឹងមិនចង់ជួយដោះស្រាយទេ ប្រសិនបើយោបល់របស់ពួកគេមិនត្រូវបានយកចិត្តទុកដាក់។

សុខភាពបរិស្ថាន គឺតែងតែជាបញ្ហារបស់សហគមន៍ទាំងមូល ដូច្នេះវាត្រូវការឲ្យប្រជាជនធ្វើការរួមគ្នាដើម្បីធ្វើការកែលម្អ។ មិនថាគោលបំណងគឺដើម្បីកាត់បន្ថយគ្រោះថ្នាក់នៃការរាតត្បាតជំងឺ, ដើម្បីដាំដំណាំប្រចាំសហគមន៍, ដើម្បីកែលម្អសុខភាពនិងសុវត្ថិភាពរបស់ប្រជាជនដែលរស់នៅក្បែររោងចក្រ ឬធ្វើការក្នុងអណ្តូងរ៉ែ, ឬដើម្បីគូសបញ្ជាក់អំពីបញ្ហាសុខភាពបរិស្ថានដទៃទៀតទេ, ដរាបណាប្រជាជនមានការយល់ដឹងដូចគ្នាអំពីបញ្ហានីមួយៗ និងមានការប្តេជ្ញារួមគ្នាក្នុងការដោះស្រាយបញ្ហាទាំងនេះ នោះពួកគេក៏នឹងកាន់តែមានជោគជ័យខ្លាំងឡើង។

## ស្ត្រីត្រូវការបញ្ចេញយោបល់

នៅសហគមន៍ខ្លះ ស្ត្រីនិងក្មេងស្រីទំនងជានឹងចូលរួមក្នុងសកម្មភាពផ្សេងៗ បើសកម្មភាពទាំងនោះត្រូវបានរៀបចំដោយដាក់ដោយឡែកពីក្រុមបុរស។ បន្ទាប់មក ក្រុមរបស់ស្ត្រីនឹងបង្ហាញពីគំនិតរបស់ពួកគេទៅកាន់ក្រុមធំៗ។ តាមវិធីនេះ ស្ត្រីនិងក្មេងស្រីមានឱកាសបញ្ចេញយោបល់រួមគ្នាមួយ មុននឹងបញ្ចេញទៅកាន់សហគមន៍ទាំងមូល។ តាមរយៈការពង្រឹងសំឡេងរបស់ស្ត្រីនិងក្មេងស្រី និងការបង្កើតជំនាញភាពជាអ្នកដឹកនាំដល់ពួកគេ, សហគមន៍ទាំងមូលនឹងកាន់តែមានភាពរឹងមាំ។




**ប្រសិនបើអ្នកចង់ដោះស្រាយបញ្ហាអ្វីមួយ អ្នកគួរធ្វើការជាមួយមនុស្សដែលរងផលប៉ះពាល់ពីបញ្ហានោះ។**

# ការពិភាក្សាដែលមានការណែនាំ

ដើម្បីឲ្យមានការយល់ដឹងដូចគ្នាលើបញ្ហាសុខភាពនានា ប្រជាជនត្រូវតែជជែកគ្នា។ ការពិភាក្សាដែលមានការណែនាំ គឺជាវិធីមួយដើម្បីឲ្យមនុស្សមួយក្រុមនិយាយជាមួយគ្នា និងដើម្បីសួរនិងឆ្លើយសំនួរជាក់លាក់មួយចំនួន។ សកម្មភាព "ប៉ុន្តែហេតុអ្វី..." (មើលទំព័រ7, 12, 38, 48 និង422) គឺជាប្រភេទមួយនៃការពិភាក្សាដែលមានការណែនាំ។ គំនូរសម្រាប់ការពិភាក្សា(មើលទំព័រ59 និង260) និងការគូសខ្សែបន្ទាត់រូបរាងមនុស្ស (មើលទំព័រ266) ក៏ជាប្រភេទនៃការពិភាក្សាដែលមានការណែនាំផងដែរ។

អ្នកដែលណែនាំការពិភាក្សា ជួនកាលត្រូវបានហៅថា អ្នកសម្របសម្រួល ឬអ្នកជីវចល។ សកម្មភាពភាគច្រើននៅក្នុងសៀវភៅនេះ តម្រូវឲ្យមានអ្នកសម្របសម្រួលម្នាក់ ដើម្បីធានាថាអ្នកចូលរួមគ្រប់គ្នាបានធ្វើការអស់ពីលទ្ធភាព និងដើម្បីធានាថាការពិភាក្សាឬសកម្មភាពនោះនឹងឈានដល់ការអនុវត្តជាក់ស្តែង។

# ការគូរផែនទីសហគមន៍

ការគូរផែនទីសហគមន៍ គឺជាសកម្មភាពមួយដែលប្រជាជននឹងធ្វើផែនទីមួយរួមគ្នា ដោយផ្អែកលើអ្វីដែលពួកគេមើលឃើញនិងយល់ដឹងនៅក្នុងសហគមន៍របស់ខ្លួន។ តាមរយៈការធ្វើផែនទីសុខភាពសហគមន៍ អ្នកអាចយល់ដឹងអំពី ៖

- ទីកន្លែងដែលបញ្ហាសុខភាពផ្សេងៗបានកើតឡើង។
- ជនដែលរងផលប៉ះពាល់ពីបញ្ហាទាំងនោះ។
- របៀបដែលស្ថានភាពបរិស្ថានអាចបណ្តាលឲ្យមានបញ្ហាសុខភាពទាំងនោះ។



**គូរផែនទីដោយប្រើប៊ិចឬថ្នាំពណ៌នៅលើក្រដាស ឬនៅលើដី ដោយប្រើថ្ម ឈើ និងអ្វីផ្សេងទៀតដែលមាន។**

ការធ្វើផែនទី អាចជួយប្រជាជនឲ្យមើលឃើញពីលំណាំផ្សេងៗនៃបញ្ហាសុខភាព, ចាប់ផ្តើមស្វែងរកមូលហេតុឫសគល់នៃបញ្ហាទាំងនេះ, និងមើលឃើញពីរបៀបដែលស្ថានភាពក្នុងសហគមន៍បានប្រែប្រួលក្នុងពេលកន្លងមក។ ផែនទីក៏អាចជួយប្រជាជនឲ្យកំណត់អំពីធនធាន និងកម្លាំងសំខាន់ៗរបស់សហគមន៍ ដែលពួកគេប្រហែលជាមិនបានចាប់អារម្មណ៍។ ហើយការធ្វើផែនទី អាចជាជំហានមួយក្នុងការការពារទីកន្លែងប្រពៃណី ឬទីសក្តិសិទ្ធសំខាន់ៗផងដែរ។ (សម្រាប់ឧទាហរណ៍អំពីការធ្វើផែនទី សូមមើលទំព័រ68, 164, និង444)។

# ការស្វែងយល់អំពីអ្វីដែលសហគមន៍ត្រូវការ

ជាញឹកញាប់ ប្រជាជនមានគំនិតខុសៗគ្នាអំពីអ្វីដែលជាបញ្ហានៅក្នុងសហគមន៍ និងអំពីអ្វីដែលជាវិធីល្អបំផុតក្នុងការដោះស្រាយបញ្ហាទាំងនោះ។ ការធ្វើឲ្យប្រជាជនគ្រប់គ្នាយល់អំពីបញ្ហាផ្សេងៗដែលកំពុងកើតឡើង និងអំពីមូលហេតុផ្សេងៗនៃបញ្ហា, និងការជួយប្រជាជនឲ្យសម្រេចចិត្តថាគួរដោះស្រាយបញ្ហាណាខ្លះក្នុងរយៈពេលខ្លី និងបញ្ហាណាខ្លះក្នុងរយៈពេលវែង, ជួនកាលត្រូវបានហៅថា "ការវាយតម្លៃលើសេចក្តីត្រូវការ"។ (សម្រាប់ឧទាហរណ៍បន្ថែមអំពីសកម្មភាពនៃការវាយតម្លៃលើសេចក្តីត្រូវការ សូមមើលទំព័រ72, 110, និង 221)។ ការវាយតម្លៃលើសេចក្តីត្រូវការ ដែលប្រព្រឹត្តទៅបានល្អ អាចជួយធ្វើឲ្យប្រាកដថា តម្រូវការ និងសមត្ថភាពរបស់មនុស្សគ្រប់គ្នា ត្រូវបានពិចារណានៅក្នុងពេលរៀបចំផែនការ។

# ការដើរសង្កេតមើលបញ្ហាសុខភាព



ក្នុងពេលដើរសង្កេតមើលបញ្ហាសុខភាព ប្រជាជនក្រឡេកមើលលើសហគមន៍របស់ពួកគេកាន់តែច្បាស់ថែមទៀត។ ពួកគេព្យាយាមស្វែងរកនូវអ្វីដែលអាចជាមូលហេតុនៃបញ្ហាសុខភាពផ្សេងៗ ដូចជាប្រភពទឹកដែលមិនស្អាត, ក្រុមហ៊ុនដែលបង្កការបំពុល, ឬការខ្វះខាតឧស។ នៅពេលប្រជាជនជាក្រុម ដើរសង្កេតមើលបញ្ហាសុខភាពរួមគ្នា ពួកគេអាចចែករំលែកគ្នានូវបញ្ហាខុសៗគ្នាដែលពួកគេបានយល់ដឹង។ បន្ទាប់មកពួកគេអាចធ្វើការជាមួយគ្នាដើម្បីរកដំណោះស្រាយផ្សេងៗដែលអាចធ្វើបាន។ ប្រជាជនចូលរួមជាមួយគ្នាកាន់តែច្រើន គំនិតក៏មានកាន់តែល្អ។ (សម្រាប់ឧទាហរណ៍អំពីការដើរសង្កេតមើលបញ្ហាសុខភាព, សូមមើលទំព័រ391 និង443)។

# ការផ្លាស់ប្តូរតាមពេលវេលា

វិធីមួយទៀតដើម្បីស្វែងយល់ពីបញ្ហានិងតម្រូវការផ្សេងៗនៅក្នុងសហគមន៍ គឺការប្រៀបធៀបស្ថានភាពបច្ចុប្បន្នជាមួយនឹងស្ថានភាពអតីតកាល។ បន្ទាប់មក គិតអំពីស្ថានភាពនាពេលអនាគត ថាតើអ្នកចង់ឲ្យវាទៅជាបែបណា។ វិធីមួយក្នុងការធ្វើបែបនេះ គឺការប្រមូលរឿងរ៉ាវផ្សេងៗ ពីមនុស្សចាស់នៅក្នុងសហគមន៍របស់អ្នក។

ការជំរុញឲ្យមនុស្សវ័យក្មេងធ្វើជាអ្នកដឹកនាំសកម្មភាពទាំងនេះ ជួយធ្វើឲ្យមានការគោរពនិងយល់ចិត្តគ្នារវាងមនុស្សក្នុងជំនាន់មួយទៅជំនាន់មួយទៀត។ វាក៏ជួយអភិរក្សនូវប្រពៃណីផ្សេងៗដែលមនុស្សគ្រប់គ្នាចង់ឲ្យនៅស្ថិតស្ថិរគង់វង្សផងដែរ។

ពេលវេលាដែលកន្លងទៅនៅក្នុងសហគមន៍ អាចជួយប្រជាជនឲ្យយល់អំពីការផ្លាស់ប្តូរពីជំនាន់មួយទៅជំនាន់មួយ និងអាចពិចារណាលើព្រឹត្តិការណ៍សំខាន់ៗ ដូចជាការក្រាលផ្លូវ, ការបើកដំណើរការរោងចក្រ, ការសាងសង់ទំនប់ ។ល។ ការគូរផែនទីអំពីការផ្លាស់ប្តូរនៅក្នុងសហគមន៍ គឺជាវិធីមួយផ្សេងទៀតក្នុងការចែករំលែកនូវចំណេះដឹងអំពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រផ្សេងៗ តាមរយៈរូបគំនូរ ឬផែនទីដែលបង្ហាញពីការផ្លាស់ប្តូរកន្លងមកនៅក្នុងស្រែចម្ការ, កសិដ្ឋាន, ព្រៃឈើ, ផ្ទះសម្បែង, ទន្លេ, និងបឹងនានា។ (សម្រាប់ឧទាហរណ៍ សូមមើលទំព័រ164)។

# សកម្មភាពគូររូប

ការគូររូបនិងការសំឡឹងមើលរូបគំនូរ អាចជួយយើងឲ្យមើលឃើញនូវដំណោះស្រាយមួយចំនួនដែលយើងមិនធ្លាប់មើលឃើញ។ រូបគំនូរអាចត្រូវបានប្រើប្រាស់ដើម្បីចាប់ផ្តើមការពិភាក្សា ហើយវាក៏អាចជាវិធីមួយដែលអនុញ្ញាតឲ្យអ្នកមិនចេះអក្សរ បង្ហាញពីមតិយោបល់របស់ខ្លួន និងចូលរួមក្នុងការដឹកនាំក្រុមផងដែរ។ (សម្រាប់ឧទាហរណ៍នៃសកម្មភាពគូររូប សូមមើលទំព័រ50, 54, និង275)។

សហគមន៍ខ្លះធ្វើការជាមួយគ្នាដើម្បីគូររូបនៅលើជញ្ជាំងអាគារ ដែលបង្ហាញពីបញ្ហារបស់ពួកគេ និងក្តីសង្ឃឹមរបស់ពួកគេនៅថ្ងៃអនាគត ថានឹងមានសុខភាពប្រសើរឡើង។ (សម្រាប់គំនិតផ្សេងៗក្នុងការបង្កើតនិងប្រើប្រាស់រូបគំនូរសម្រាប់ការអប់រំតាមសហគមន៍ សូមមើលសៀវភៅ ការជួយបុគ្គលិកសុខាភិបាលឲ្យរៀន របស់អង្គការហេស្ពើរៀន។



## ការស្ទង់មតិក្នុងសហគមន៍

ការស្ទង់មតិក្នុងសហគមន៍ គឺជាវិធីមួយដែលត្រូវបានរៀបចំជាមុនដើម្បីប្រមូលព័ត៌មានផ្សេងៗ។ វាអាចត្រូវបានប្រើប្រាស់ដើម្បីស្វែងយល់អំពីបញ្ហាសុខភាពរបស់ប្រជាជន, ដើម្បីពិចារណាលើភាពដូចគ្នានិងខុសគ្នាចំពោះអ្វីដែលប្រជាជនយល់ឃើញ, ឬដើម្បីវាស់ស្ទង់ពីការគាំទ្ររបស់ប្រជាជនទៅលើផែនការឬសកម្មភាពផ្សេងៗនៅក្នុងសហគមន៍។



នៅក្នុងការស្ទង់មតិ ប្រជាជនទាំងអស់ដែលចូលរួម នឹងត្រូវបានសួរសំនួរដូចៗគ្នា ក្នុងរបៀបតែមួយ។ ការស្ទង់មតិអាចធ្វើឡើងនៅក្នុងផ្ទះ, កន្លែងធ្វើការ, សាលារៀន, ទីសក្ការៈ, កន្លែងដែលប្រជាជនជួបជុំគ្នា, ឬសូម្បីតែតាមការនិយាយទូរស័ព្ទ ឬធ្វើតាមប្រៃសណីយ៍។

ការស្ទង់មតិអនុញ្ញាតឲ្យអ្នកចូលរួម ចែករំលែកនូវគំនិតយោបល់របស់ខ្លួនជាលក្ខណៈឯកជន ដោយមិនចាំបាច់ទៅចូលរួមក្នុងការប្រជុំ ឬក្នុងព្រឹត្តិការណ៍សារធារណៈដទៃទៀតទេ។ បែបនេះអាចជាវិធីមួយសម្រាប់មនុស្សមួយចំនួនដែលមានការភ័យខ្លាច ឬមិនត្រូវបានអនុញ្ញាតឲ្យចូលរួមក្នុងការសម្រេចចិត្តរបស់សហគមន៍ខ្លួន ដើម្បីឲ្យការបារម្ភនិងគំនិតរបស់ពួកគេត្រូវបានពិចារណា។ (សម្រាប់ឧទាហរណ៍អំពីការស្ទង់មតិផ្នែកសុខភាពក្នុងសហគមន៍, សូមមើលទំព័រ500 ដល់505 ដែលមានចំណងជើងថា "សហគមន៍ដែលរងការប៉ះពាល់ពីប្រេង រៀបចំការសិក្សាផ្នែកសុខភាពមួយ" )។

## ល្ខោន

ល្ខោនគឺជាវិធីមួយដើម្បីពិនិត្យរកមើលបញ្ហាផ្សេងៗ និងស្នើឡើងនូវដំណោះស្រាយមួយចំនួន ខណៈដែលផ្តល់ការកំសាន្តនិងសប្បាយរីករាយ។ ប្រជាជនអាចសម្តែងចេញនូវបទពិសោធន៍ផ្ទាល់ខ្លួន និងស្រមើស្រមៃពីបទពិសោធន៍របស់អ្នកដទៃ។ បញ្ហានិងជម្លោះមួយចំនួនអាចប្រែក្លាយជាងាយពិចារណា ប្រសិនបើវាត្រូវបានបង្ហាញនៅពេលវេលានិងទីកន្លែងដទៃវិញ។ (មើលទំព័របន្ទាប់ អំពីវិធីរៀបចំល្ខោន)។

# ល្ខោនសង្គម

ល្ខោនសង្គមអនុញ្ញាតឲ្យប្រជាជនសម្តែងចេញនូវបញ្ហាមួយ រួចបង្ហាញពីមូលហេតុនិងផលប៉ះពាល់មួយចំនួននៃបញ្ហានោះ។ ឧទាហរណ៍មួយនៅទំព័រ186 ដល់188 បង្ហាញពីរបៀបសម្តែងល្ខោនសង្គម ដែលនិយាយអំពីជម្លោះលើធនធានព្រៃឈើ។

ល្ខោនសង្គមអាចបំផុសនូវមនោសញ្ចេតនាយ៉ាងជ្រាលជ្រៅ។ អ្នករៀបចំសហគមន៍ខ្លះ ចូលចិត្តបញ្ចប់សាច់រឿងដោយឲ្យប្រជាជនច្រៀងចម្រៀងមួយបទរួមគ្នា ឬធ្វើសកម្មភាពដទៃទៀតដែលមានលក្ខណៈជាការសហការគ្នា។

ល្ខោនអន្តរកម្ម គឺជាប្រភេទមួយនៃល្ខោនសង្គម ដែលមនុស្សគ្រប់គ្នាទស្សនាផង និងចូលរួមសម្តែងផង។ ទស្សនិកជនណាម្នាក់ ក៏អាចប្រាប់អ្នកសម្តែងឲ្យឈប់បានដែរ រួចគាត់អាចចូលសម្តែងជំនួសតួនោះ ដោយសម្តែងអំពីដំណោះស្រាយផ្សេងមួយទៀត។ បែបនេះមានប្រយោជន៍ជាពិសេសចំពោះស្ថានភាពខ្លះ ដែលប្រជាជនផ្លាស់ប្តូរវេនគ្នាសម្តែងតួរបស់មនុស្សម្នាក់ដែលមានអំណាចតិចតួចឬគ្មានសោះ។



រឿងរ៉ាវអ្វីក៏ដោយក៏អាចយកធ្វើជាល្ខោនសង្គមបានដែរ ដរាបណាវាមានតួអង្គក្នុងនោះ និងមានបញ្ហាដែលត្រូវដោះស្រាយ។

### ការសម្តែងតួ

ការសម្តែងតួមិនទាមទារឲ្យមានការរៀបចំច្រើនដូចល្ខោនសង្គមទេ ហើយវាអាចជួយពន្យល់អំពីគំនិតខុសៗគ្នា ឬជួយដោះស្រាយជម្លោះផ្សេងៗ។ ប្រជាជនដើរតួខុសៗគ្នា ដោយសម្តែងពីស្ថានភាពក្នុងជីវិតពិត ដើម្បីបង្ហាញនូវអ្វីដែលពួកគេនឹងធ្វើ។ អ្នកអាចពិភាក្សានិងសម្តែងតួឡើងវិញ ដើម្បីស្វែងយល់ថាហេតុអ្វីបានជាប្រជាជនបញ្ចេញអាកប្បកិរិយាបែបនោះ។

នៅលើឆាកសម្តែង ការកែប្រែអាកប្បកិរិយារបស់មនុស្សម្នាក់ដែលមានអំណាច គឺជាការងាយស្រួលទេ ប៉ុន្តែការកែប្រែក្នុងជីវិតពិត គឺពិបាកណាស់។ ការអនុវត្តក្នុងឆាកល្ខោនអំពីរបៀបទំនាក់ទំនងជាមួយមនុស្សមានអំណាចលើយើង ជួយត្រៀមលក្ខណៈដល់ប្រជាជនឲ្យចេះប្រើវិធីផ្សេងៗក្នុងការឆ្លើយតបទៅកាន់អ្នកមានអំណាចក្នុងជីវិតពិត។



### ការសម្តែងតុក្កតា

ការសម្តែងតុក្កតា គឺគេយកតុក្កតាមកសម្តែងជំនួសមនុស្ស ដើម្បីបង្ហាញពីសាច់រឿងនៃជម្លោះក្នុងសហគមន៍។ វាធ្វើឲ្យប្រជាជនសើច ហើយអាចជួយពួកគេឲ្យមើលឃើញនូវអ្វីដែលមិនធ្លាប់មើលឃើញពីមុន។ មនុស្សខ្លះអាចនិយាយតាមរយៈតុក្កតាបានងាយជាងការសម្តែងនៅលើឆាក។

# ការណែនាំអំពីពេលវេលាដែលគួរប្រើសកម្មភាពនីមួយៗ

សកម្មភាពទាំងឡាយនៅក្នុងសៀវភៅនេះ មានសារសំខាន់សម្រាប់ការពិនិត្យរកមើលបញ្ហាសុខភាពបរិស្ថានជាក់លាក់មួយចំនួនដែលមាននៅក្នុងជំពូកនីមួយៗ។ ហើយវាអាចជួយអ្នកឲ្យបោះជំហានទៅមុខទៀតនៅពេលរៀបចំសកម្មភាពនៅក្នុងសហគមន៍របស់អ្នក។



សកម្មភាពទាំងនេះអាច ៖

- ជួយស្វែងយល់អំពីបញ្ហាផ្សេងៗ ឬចាប់ផ្តើមការសន្ទនាអំពីប្រធានបទជាក់លាក់មួយ (មើលទំព័រ59, 69, 72, 260, និង468)។



- ជួយក្រុមមួយឲ្យសម្រេចចិត្ត ឬជ្រើសរើសរវាងតម្រូវការ និងជម្រើសជាច្រើនខុសៗគ្នា (មើលទំព័រ138 និង191)។
- ជួយប្រមូលព័ត៌មាន, ចែករំលែកចំណេះដឹង, និងកែប្រែការយល់ឃើញរបស់យើងចំពោះបរិស្ថានរបស់យើងនិងខ្លួនយើង (មើលទំព័រ50, 54, 90, 391, និង443)។
- ជួយឲ្យរៀនសូត្រពីគំនិតថ្មីៗ, រៀនសាឡើងវិញពីគំនិតដែលយើងដឹងរួចមកហើយ, ឬរៀនសូត្រពីគំនិតចាស់ៗតាមរបៀបថ្មីវិញ (មើលទំព័រ158, 284, 289, 336, និង514)។
- ជួយឲ្យចាប់ផ្តើមការរៀបចំសកម្មភាពដើម្បីដោះស្រាយបញ្ហាជាក់លាក់ណាមួយ (មើលទំព័រ110, 164, 221, និង275)។
- ជួយបង្រៀនពីគំនិតពិបាកៗ ឬជួយស្វែងយល់និងដោះស្រាយជម្លោះ (មើលទំព័រ110 និង186)។

សកម្មភាពខ្លះអាចត្រូវបានប្រើប្រាស់ជាមួយគ្នាបាន ដូចជាការគូរផែនទីសហគមន៍ក្នុងពេលឬក្រោយពេលការដើរសង្កេតមើលបញ្ហាសុខភាពរួច, ឬយកការសម្តែងតួធ្វើជាផ្នែកមួយនៃសកម្មភាពវាយតម្លៃលើសេចក្តីត្រូវការរបស់ប្រជាជន។ អ្វីដែលសំខាន់បំផុតគឺថា សកម្មភាពទាំងនេះជួយប្រជាជនក្នុងការប្រមូលព័ត៌មាន, ចែករំលែកចំណេះដឹង, និងធ្វើឲ្យមានការយល់ចិត្តគ្នាកាន់តែជ្រាលជ្រៅ។ ចំណុចនេះនឹងជួយគាំទ្រដល់ការរៀបចំ, ការផ្តល់អំណាច, និងការងាររបស់ពួកគេក្នុងការដោះស្រាយមូលហេតុឫសគល់នៃបញ្ហាសុខភាពទាំងឡាយនៅក្នុងសហគមន៍។

